**Weekly Bulletin (Week3) May, 2010**

ព្រឹត្តិបត្រ ព័ត៌មានប្រចាំសប្តាហ៍
កសិកម្ម និងអភិវឌ្ឍន៍ជនបទ

## ការចាប់ផ្តើមកែលម្អគុណភាពអង្ករសម្រាប់ការនាំចេញ

*(វិទ្យុអូស្ត្រាលី ២៤ ឧសភា ២០១០)*

អ្នកជំនួញអង្ករមកពីបណ្តាប្រទេសអឺរ៉ុបបានមកកម្ពុជា ដើម្បីជួបជាមួយមន្ត្រីសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា រួមជាមួយម្ចាស់រោងម៉ាស៊ីនកិនស្រូវផងដែរ ដើម្បីចាប់ផ្តើកែលម្អគុណភាពអង្ករ។ លោកម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មមានប្រសាសន៍ថា មានបញ្ហាពីរដែលភាគីកម្ពុជាត្រូវដោះស្រាយដើម្បីឈានទៅដល់ការនាំអង្ករចេញទៅក្រៅប្រទេស គឺគុណភាពកិនអង្កររបស់រោងម៉ាស៊ីនកិនស្រូវនៅមានកំរិតទាប (តែត្រូវបានដោះស្រាយ ដោយយើងបាននាំចូលម៉ាស៊ិនកិនស្រូវទំនើបជាងមុន) និងបញ្ហាពូជស្រូវមិនសុទ្ធល្អ។ លោកមៅ ថូរ៉ា ឱ្យដឹងថា អ្នកពាណិជ្ជកម្មពីអឺរ៉ុប បានសន្យានឹងបញ្ជូនអ្នកជំនាញឱ្យមកបង្រៀនមន្ត្រីកម្ពុជា អំពីរបៀបវេចខ្ចប់អង្ករ ការដឹកជញ្ជូន និងបែបបទបញ្ជូនប្រាក់តាមរយៈឥណទាន។ មន្ត្រីកសិកម្មបានបញ្ជាក់ថា កម្ពុជាមានអង្ករសល់ពីហូប ហើយអាចនាំចេញប្រមាណ **៣លានតោនអង្ករ**ក្នុងមួយឆ្នាំៗ។

## កម្ពុជាអាចទទួលបានជំនួយរាប់ពាន់លានដុល្លារ

*(វិទ្យុអូស្ត្រាលី ២៤ ឧសភា ២០១០)*

សហរដ្ឋអាមេរិកបានជ្រើសរើសយកប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង ២០សម្រាប់កញ្ចប់ជំនួយដែលមានទឹកប្រាក់រាប់ពាន់លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងជាមួយការស្រេឃ្លានអាហារ ដោយជម្រុញការធ្វើកសិដ្ឋាន និងកសិកម្ម។ ប្រធានទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ លោក Rajiv Shah និយាយថា សហរដ្ឋអាមេរិកនឹងផ្តល់ជំនួយយ៉ាងហោចណាស់ ៣ពាន់ ៥រយលានដុល្លារអាមេរិកសម្រាប់រយៈពេល ៣ឆ្នាំនៅក្នុងផែនការបង្កើតអាហារសម្រាប់អនាគត។ ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំងបួន ដែលគេយកចិត្តទុកដាក់នៅក្នុងទ្វីបអាស៊ី ដែលរួមមានប្រទេសបង់ក្លាដេស នេប៉ាល់ និងប្រទេសតាជីគីស្ថាន។

## កំណើននាំចេញសម្លៀកបំពាក់ត្រីមាសទី១

*(អេវើរីដេ ២៤ ឧសភា ២០១០)*

ការនាំចេញសម្លៀកបំពាក់និងផលិតផលតម្បាញនៅក្នុងត្រីមាសទី១ដើមឆ្នាំ២០១០កើន ឡើង៧,២៩ភាគរយ បើធៀបនឹងរយៈពេលដូចកាលពីឆ្នាំមុន ។ នេះបើ តាមតួលេខផ្លូវការដែលកាសែត ភ្នំពេញប៉ុស្តិ៍ទទួលបានកាល ពីចុងសប្តាហ៍មុនពីនាយកដ្ឋានស្ថិតិនិងព័ត៌មាននៃក្រសួងពាណិជ្ជកម្ម ។ ស្ថិតិខាងលើ បានឱ្យដឹងថាក្នុងរយៈពេលបីខែកន្លងទៅនេះកម្ពុជា បាននាំចេញសម្លៀក

បំពាក់និងផលិតផលតម្បាញទៅកាន់ទីផ្សារអាមេរិកអឺរ៉ុបកាណាដានិងទីផ្សារផ្សេងៗ មានទឹកប្រាក់ សរុប៦០៣លានដុល្លារច្រើនជាងបីខែដំបូងឆ្នាំ២០០៩មានត្រឹមតែ៥៦២លានដុល្លារ។ ទោះយ៉ាងណាបើពិនិត្យទៅលើការ នាំចេញសម្រាប់ខែមីនា តួលេខបានបង្ហាញថាការនាំចេញកើនតែ០,៧០ភាគរយប៉ុណ្ណោះគឺមានទឹកប្រាក់សរុប១៧៨,២៥លានដុល្លារខណៈការនាំចេញនៅខែមីនាឆ្នាំ មុនមានទឹកប្រាក់សរុប១៧៧,០១លានដុល្លារ ។ លោក គង់ពុទ្ធារ៉ាប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មាននៃ ក្រសួងពាណិជ្ជកម្មប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃអាទិត្យថាការកើនឡើង បរិមាណនាំចេញសម្លៀកបំពាក់ក្នុងត្រីមាសដំបូងនៅឆ្នាំនេះគឺជាសញ្ញាវិជ្ជមានមួយធ្វើឱ្យមានសេចក្តីសង្ឃឹមថាការនាំចេញឆ្នាំនេះអាចល្អប្រសើរជាងឆ្នាំមុន។

## ក្រុមហ៊ុនអូស្រ្តាលីរកឃើញមាសចំនួន ៨.១លានតោននៅកម្ពុជា

*(ដើមអំពិល ២៤ ឧសភា ២០១០)*

មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជាឱ្យដឹងថា ក្រុមហ៊ុនរុករករ៉ែកម្ពុជា OZ បានរករ៉ែមាសចំនួន ៨.១លានតោននៅស្រុកកែវសីម៉ាខេត្តមណ្ឌលគីរី។ លោកសុខ ឡេង ប្រធាននាយកដ្ឋានធនធានរ៉ែនិងថាមពលនៃក្រសួងថាមពលឱ្យដឹងថា មានក្រុមហ៊ុនជាតិនិងអន្តរជាតិចំនួន ៦០មកពីអូស្រ្តាលី ចិន វៀតណាម និងកូរ៉េ បានទទួលអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាលចាប់តាំងពីឆ្នាំ ២០០៤ក្នុងការសិក្សារុករករ៉ែ នៅកម្ពុជា។

## ពាណិជ្ជកម្មឆ្លងដែនរវាងកម្ពុជា និងវៀតណាមកើនឡើង

*(វិទ្យុអាស៊ីសេរី ២៤ ឧសភា ២០១០)*

ពាណិជ្ជកម្មឆ្លងដែនរវាងប្រទេសកម្ពុជា និងវៀតណាមបានកើនឡើងជាង ៣០%នៃអត្រាប្រចាំឆ្នាំ។ ប្រភពព័ត៌មានរបស់កាសែតវៀតណាមដោយស្រង់សំដីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាមឱ្យដឹងថា ពាណិជ្ជកម្មរវាងប្រទេសកម្ពុជានិងវៀតណាមកាលពីឆ្នាំកន្លងទៅមានទឹកប្រាក់សរុបជាង ១៤ពាន់លានដុល្លារសហរដ្ឋអាមេរិក ដែលមានកំណើនជាង ៣០%។ លោកបន្តថា នៅត្រីមាសទី១ នៃឆ្នាំ ២០១០នេះ ការផ្លាស់ប្តូរទំនិញនៃប្រទេសទាំងពីរមានទឹងប្រាក់សរុបជាង ៤០០លានដុល្លារសហរដ្ឋអាមេរិក គឺកើនចំនួន ១២៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០០៩។ រដ្ឋាភិបាលនៃប្រទេសទាំងពីរបានព្រមព្រៀងគ្នាក្នុងកិច្ចសហប្រតិបត្តិការ ដើម្បីឈានដល់ការផ្លាស់ប្តូរទំនិញឱ្យដល់ទឹកប្រាក់ ២ពាន់លានដុល្លានៅឆ្នាំ ២០១០ និង ឱ្យដល់ ៦៥០០លានដុល្លារក្នុងមួយឆ្នាំ នៅឆ្នាំ ២០១៥។

## សិក្ខាសាលាទប់ស្កាត់ការនាំជ្រូក និងត្រីចូលពីបរទេស

*(វីអូអេ ២០ ឧសភា ២០១០)*

ក្រុមអាជីវករខ្នាតតូច និងមន្ត្រីរដ្ឋាភិបាលកម្ពុជា បានជួបប្រជុំគ្នាដើម្បីរិះរកវិធីទប់ស្កាត់ការនាំចូលជ្រូក និងត្រីពីបរទេស។ លោក Curtis Hundley ប្រធានគម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត តូច និងមធ្យមមានប្រសាសន៍ថា ការនាំជ្រូកពីប្រទេសជិតខាងក្នុងមួយឆ្នាំៗប្រមាណជាង ១លានក្បាល ដែលធ្វើកម្ពុជាបានបាត់បង់ប្រាក់ចំនួន ៤៥លានដុល្លារសហរដ្ឋអាមេរិកក្នុង ១ឆ្នាំ។

## ក្រសួងធនធានទឹកមានយន្តហោះសម្រាប់ថតរូបលើអាកាស

*(រស្មីកម្ពុជា ២០ ឧសភា ២០១០)*

លោកលឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយមមានប្រសាសន៍ឱ្យដឹងកាលពីពេលថ្មីៗនេះថាក្រសួងមានយន្តហោះផ្ទាល់ ខ្លួនហើយយន្តហោះនេះប្រើប្រាស់សម្រាប់ការថតរូបពីលើអាកាសដើម្បីបម្រើវិស័យការងារធនធានទឹក។ រូបថត ថតតាមយន្តហោះវាមានភាពសុក្រឹតជាងរូបថតដែលថតតាមផ្កាយរណប ។ ចាប់ពីពេលនេះទៅមិនអាចអ្នកណានិយាយកុហកបានទៀតទេ។ ក្រៅពីទើបមានយន្តហោះមួយគ្រឿងនេះ លោករដ្ឋមន្ត្រីក្រសួងធនធានទឹកមានប្រសាសន៍ឱ្យដឹងទៀតថា ក្រសួងនឹងទទួលបានគ្រឿង ចក្រចំនួនប្រមាណជាពី៧០-៨០គ្រឿងពីប្រទេសជប៉ុនក្នុងពេលឆាប់ៗខាងមុខនេះ។ គ្រឿងចក្រដែលនឹងទទួលបាននេះក្រសួងមានផែនការបែងចែកជាក្រុមចំនួនពី ៤ទៅ ៥ភូមិភាគដើម្បីធ្វើអនុត្តរភាពប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេសឱ្យបានសម្រេចគោលដៅ របស់ក្រសួងនៅក្នុងអាណត្តិនេះ ។

ក្រសួងធនធានទឹកនិងឧតុនិយមកាលពីពេលថ្មីៗកន្លងទៅនេះ បានដាក់ចេញនូវផែនការអនុត្តរភាពប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេសដើម្បីឱ្យទឹកបានហូរទៅដល់ស្រែសម្រាប់ប្រជាកសិករបង្កបង្កើនផលស្រូវ ។

លោកលឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយមមានប្រសាសន៍នៅក្នុងកិច្ចប្រជុំពិភាក្សាការងារលើវិស័យធនធានទឹកឆ្នាំ ២០១០កាលពីពេលកន្លងទៅថ្មីៗនេះថាដើម្បីឱ្យទឹកបានចូលទៅដល់ស្រែក្រសួងនៅរក្សាយុទ្ធសាស្ត្រដដែល តែប្តូរយុទ្ធវិធីគឺការងារធារាសាស្ត្រធំៗថ្នាក់កណ្តាល(ក្រសួង)ជាអ្នកធ្វើតែការធ្វើអនុត្តរភាពឱ្យប្រព័ន្ធមានគ្រប់លក្ខណៈនិងមាននិរន្តរភាពនោះគឺជាភារកិច្ចសំខាន់របស់មន្ទីរនីមួយៗជាអ្នកលើកគម្រោងនិងអនុវត្ត ឯថ្នាក់កណ្តាលជាអ្នករកថវិកានិងដៃគូផ្តល់ឱ្យ ។ នៅចំពោះមុខគ្រប់មន្ទីរត្រូវតែលើកគម្រោងធ្វើប្រឡាយបន្តពីអាងដើម្បីបានទឹកទៅជិតដល់ស្រែ ។ ឯសំណង់ស្នាក់ទឹកយើងធ្វើតាមក្រោយ តាមលទ្ធភាព ។សំណង់ធារាសាស្ត្រដែលយើងមានគឺមិនទាន់គ្រប់លក្ខណៈទេដោយសារទុនរបស់យើងមានកម្រិតទឹកយើងមិនទាន់ហូរចូលស្រែតែយើងមាននៅក្នុងអាងមាននៅក្នុងប្រឡាយហើយនាំយកទៅដល់ស្រែដោយវិធីផ្សេងៗ(បូម) ។

## រកឃើញមន្ត្រីខ្មោចជាង២ពាន់នាក់ធ្វើឱ្យរដ្ឋចំណេញជាង២លានដុល្លារក្នុងមួយឆ្នាំ

*(រស្មីកម្ពុជា ១៩ ឧសភា ២០១០)*

ការធ្វើជំរឿនមន្ត្រីរាជការទូទាំងប្រទេសលើកទី៣ដែលគ្រោងបញ្ចប់នៅចុងខែឧសភាឆ្នាំ២០១០ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលឱ្យបានហ្មត់ចត់និងធានាបាននូវប្រសិទ្ធភាពការងារនិងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈបានរកឃើញមន្ត្រីមិនប្រក្រតីចំនួនជាង២ពាន់នាក់នៅថ្នាក់ជាតិដែលធ្វើឱ្យរដ្ឋចំណេញថវិកាបានប្រមាណ ២លានដុល្លារអាមេរិកក្នុង១ឆ្នាំ ។ បើតាមរបាយការណ៍របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានឱ្យដឹងថាមកដល់ត្រឹមខែកុម្ភៈឆ្នាំ២០១០នេះចំនួនមន្ត្រីរាជការស៊ីវិលនិងប្រាក់បៀវត្សរ៍ដែលមាននៅក្នុងតារាងបើកបៀវត្សរ៍របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសដែលបានបើកបៀវត្សរ៍នៅខែកុម្ភៈឆ្នាំ២០១០មានចំនួន១៧៦.៨២៩នាក់ក្នុងនោះមានមន្ត្រីជាស្ត្រីចំនួន៦០.១៨២នាក់ ។

ក្នុងនោះក្របខ័ណ្ឌប្រភេទ"ក"មានចំនួន២៨.៥៤៧នាក់ ក្របខ័ណ្ឌប្រភេទ"ខ" មាន៥២.៧០៦នាក់ ក្របខ័ណ្ឌប្រភទ"គ"មានចំនួន ៨១.៩០០នាក់ និងក្របខ័ណ្ឌប្រភេទ"ឃ"មានចំនួន១៣.៦៧៨នាក់ ។

## កម្ពុជារៀបចំច្បាប់ ការពារផលិតផលក្នុងស្រុក

*(វិទ្យុបារាំង ១៩ ឧសភា ២០១០)*

រដ្ឋាភិបាលកម្ពុជាកំពុងរៀងចំតាក់តែងសេចក្តីព្រៀងច្បាប់ស្តីពី ឧបាស្រ័យពាណិជ្ជកម្ម ឬការដោះស្រាយពាណិជ្ជកម្ម ដើម្បីប្រឆាំងការលក់ បង្ខូចថ្លៃលើទំនិញ និងផលិតផលនានាដែលនាំចូលពីក្រៅប្រទេស ពិសេសពីប្រទេសជិតខាង។ សេចក្តីព្រាងច្បាប់នេះមាន ៦ជំពូក និង ១២៤មាត្រា ត្រូវបានតាក់តែងឡើងតាមរយៈក្រសួងពាណិជ្ជកម្ម សហការជាមួយទីភ្នាក់ងារជំនួយអភិវឌ្ឍន៍សហរដ្ឋអាមេរិក USAID ដែលច្បាប់នេះស្របតាមតម្រូវការរបស់អង្គការពាណិជ្ជកម្មពិភពលោក WTO ។

តែងសេចក្តីព្រៀងច្បាប់ស្តីពី ឧបាស្រ័យពាណិជ្ជកម្មបានកំណត់ពីនីតិវិធី និងវិធានការទាំងឡាយសម្រាប់ការអនុវត្តន៍នូវបាស្រ័យពាណិជ្ជកម្ម (ដំណោះស្រាយ) ដែលអាចដោះស្រាយចំពោះផលប៉ះពាល់ជាអវិជ្ជមាន និងការកើនឡើងយ៉ាងគំហុកនូវការនាំចូល។ ច្បាប់ថ្មីនេះ ក៏មានគោលដៅគាំទ្រដល់ការអភិវឌ្ឍន៍នៃការប្រកួតប្រជែង និងផលិតភាពរបស់ផលិតករទាំងឡាយ។

## ខ្មែរមានកម្មករកាត់ដេរ ៣២០.៧៣៤នាក់

*(អេរីវ៉េដេ ១៩ ឧសភា ២០១០)*

យោងតាមទិន្នន័យមួយរបស់រដ្ឋាភិបាលបានបង្ហាញកាលពីថ្ងៃអង្គារថា បើទោះជាមានវិបត្តិសេដ្ឋកិច្ចពិភពលោកក៏ដោយក៏វិស័យកាត់ដេរកម្ពុជានៅតែខ្លាំងទាក់ទងទៅនឹងការផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា។ ទិន្នន័យដែលផ្តល់ដោយក្រសួងពាណិជ្ជកម្មបានបង្ហាញថានាពេលបច្ចុប្បន្ននេះមានកម្មករ កាត់ដេរចំនួន៣២០.៧៣៤នាក់ក្នុងចំណោមនោះមានស្ត្រី ២៩៣.៦៦៤ នាក់កំពុងធ្វើការនៅក្នុងរោងចក្រចំនួន២៦៩កន្លែងនៅទូទាំងប្រទេស។ ទិន្នន័យនេះបានបង្ហាញថា ការនាំចេញសម្លៀកបំពាក់សរុបទៅបរទេសក្នុងឆ្នាំ ២០០៩មាន ចំនួន២.៣៨៥ លានដុល្លារក្នុងនោះចំនួន ១.៤៨៦លានដុល្លារនាំទៅកាន់ សហរដ្ឋអាមេរិក ៥៧៧លានដុល្លារទៅកាន់ ទីផ្សារអឺរ៉ុប ១៨៤លានដុល្លារទៅកាន់ប្រទេសកាណាដានិង ១៣៦លានដុល្លារទៅកាន់ប្រទេសផ្សេងៗ។

## ចំការដំឡូងមីរបស់អ្នកភូមិនៅរតនគីរីខូចខាតព្រោះគ្មានភ្លៀង

*(វិទ្យុអាស៊ីសេរី ១៨ ឧសភា ២០១០)*

កសិករជនជាតិដើមភាគតិចគ្រឹងនៅភូមិអុន ស្រុកអូរយ៉ាដាវ ឱ្យដឹងថាដើមដំឡូងមីដែលអ្នកភូមិដាំក្នុងមួយគ្រួសារ កន្លះហិកតាដល់ ២ហិកតាត្រូវក្រៀមស្វិត និងសត្វល្អិតស៊ីបំផ្លាញដោយសារគ្មានទឹកភ្លៀង។ តម្លៃដំឡូងមីក្រៀមនៅចុងឆ្នាំ ២០០៩ នៅទីផ្សារខេត្តរតនគីរីកើនឡើងពី ៥០០រៀលរហូតដល់ ៧២០រៀលក្នុង ១គីឡូក្រាម។

តួលេខស្រង់ដោយមន្ទីរកសិកម្មខេត្តឱ្យដឹងថា បរិមាណដំឡូងមីដែលកសិករដាំបានកាលពីឆ្នាំ២០០៨មានចំនួន ៧ម៉ឺនតោន ហើយធ្លាក់ចុះមកត្រឹម ៣ម៉ឺនតោននៅឆ្នាំ ២០០៩ ដោយសារតំលៃចុះទាប។

## ព្រមានឱ្យប្រុងប្រយ័ត្នពីការវាយប្រហារដោយរន្ទះ

*(វិទ្យុអូស្ត្រាលី ១៧ ឧសភា ២០១០)*

នៅពេលដែលរដូវវស្សាបានឈានមកដល់ក្នុងឆ្នាំនេះ ប្រជាពលរដ្ឋបានចាប់ផ្តើមរងគ្រោះពីបាតុភាពធម្មជាតិ ដែលមកដល់ចុងសប្តាហ៍នេះមានមនុស្សចំនួន ២០នាក់ហើយបានស្លាប់ដោយសាររន្ទះ។

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា កាលពីឆ្នាំ ២០០៨ រន្ទះបានសម្លាប់មនុស្សចំនួន ៩៥នាក់ ហើយក្នុងឆ្នាំ ២០០៩ ចំនួនមនុស្សស្លាប់ដោយសាររន្ទះបានកើនដល់ ១៤០នាក់។

## ម៉ាឡេស៊ីស្វែងរកដៃគូវិនិយោគរួមគ្នាជាមួយវិនិយោគិនកម្ពុជា

*(វីអូអេ ១៧ ឧសភា ២០១០)*

ក្រុមហ៊ុនធំៗរបស់ប្រទេសម៉ាឡេស៊ីបានចុះស្វែងរកដៃគូវិនិយោគរួមគ្នានៅប្រទេសកម្ពុជាជាលើកដំបូងដើម្បីបង្កើតគម្រោងវិនិយោគនៅក្នុងវិស័យដែលមានសក្តានុពលមួយចំនួន។ ដំណាលគ្នានេះដែរក្រុមហ៊ុនម៉ាឡេស៊ីចំនួន ៦បានចុះកិច្ចព្រមព្រៀងវិនិយោគរួមគ្នាជាមួយក្រុមហ៊ុនកម្ពុជា ក្នុងទឹកប្រាក់ ១ពាន់លានដុល្លារ។ ក្រុមហ៊ុនរបស់ម៉ាឡេស៊ីនឹងធ្វើការវិនិយោគលើការបើកហាងកាហ្វេចំនួន ២០កន្លែង ផលិតអាហារសម្រាប់បងប្អូនឥស្លាម ការបើកកសិដ្ឋានចិញ្ចឹមមាន់ ការបើកសាកលវិទ្យាល័យចំនួន ២ និងការបង្កើតកុងស៊ុលពាណិជ្ជកម្មកម្ពុជា-ម៉ាឡេស៊ីផងដែរ។ ដោយឡែកក្រុមហ៊ុនម៉ាឡេស៊ីចំនួន ៦០ផ្សេងទៀត បានសម្លឹងមើលសក្តានុពលវិនិយោគវិស័យកសិ-ឧស្សាហកម្ម ប្រេងនិងឧស្ម័នជីវៈឥន្ធនៈ អចលនទ្រព្យ ទេសចរណ៍ និងវិស័យបច្ចេកវិទ្យាទូរគមនាគមន៍ជាដើម។

## កម្ពុជាទំនងជាមិនជួបវិបត្តិហិរញ្ញវត្ថុដូចប្រទេសក្រិចទេ

*(វីអូអេ ១៧ ឧសភា ២០១០)*

ក្រុមអ្នកសេដ្ឋកិច្ចជាតិ និងអន្តរជាតិបានប៉ាន់ប្រមាណថា ប្រទេសកម្ពុជាប្រហែលជាមិនធ្លាក់ចូលនៅក្នុងវិបត្តិហិរញ្ញវត្ថុដ៏អាក្រក់ដូចប្រទេសក្រិច ដែលកើតចេញពីការគ្មានលទ្ធភាពសងបំណុលនោះទេ។ ប៉ុន្តែវាជាមេរៀនមួយសម្រាប់កម្ពុជាដើម្បីបង្កើនការប្រុងប្រយ័ត្នចំពោះស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ របាយការណ៍ឆ្នាំ ២០០៩របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្ហាញថា នៅឆ្នាំ ២០០៩ប្រទេសកម្ពុជាមានឱនភាពថវិកាចំនួន ៦% នៃផលិតផលក្នុងស្រុកសរុបដែលមានតម្លៃជិត ១០ពាន់លានដុល្លារ។ មានន័យថាប្រទេសកម្ពុជាបានចំណាយច្រើនជាងចំណូលរបស់ខ្លួនដែលភាគច្រើនជាចំណូលសារពើពន្ធនោះចំនួនជិត ៦០០លានដុល្លារ។ តួលេខនេះបានកើនឡើងទ្វេដង បើធៀបនឹងឆ្នាំ ២០០៨។ ដើម្បីបំពេញបង្គ្រប់ការចំណាយសម្រាប់ការអភិវឌ្ឍន៍នេះ ប្រទេសកម្ពុជាត្រូវពឹងផ្អែកលើជំនួយ និងកម្ចីហិរញ្ញវត្ថុពីអ្នកផ្តល់អំណោយទានបរទេស ដែលភាគច្រើនមកពីប្រទេសចិន ប្រទេសជប៉ុន និងដៃគូអភិវឌ្ឍន៍។ ជាក់ស្តែងកាលពីឆ្នាំ ២០០៩ ប្រទេសកម្ពុជាទទួលបានហិរញ្ញទានកម្ចី និងជំនួយឥតសំណងសរុបជិត ១០០០ លានដុល្លារអាមេរិក។

ភ្នាក់ងារស៊ើបការណ៍សម្ងាត់ (CIA) របស់សហរដ្ឋអាមេរិកបានប៉ាន់ប្រមាណថា រហូតមកដល់ឆ្នាំ ២០០៩ ប្រទេសកម្ពុជាជំពាក់បំណុលបរទេសជាង ៤០០០លានដុល្លារ ឬស្មើនឹង ៤០%នៃផលិតផលសរុបក្នុងស្រុក។ បំណុលនេះបានកើនឡើងជិតពីរដងបើធៀបទៅនឹងឆ្នាំ ២០០៤ ដែលមានចំនួន ២៤០០ លានដុល្លារ។ អ្នកសេដ្ឋកិច្ចមួយចំនួនព្រួយថា ប្រាក់បំណុលនេះអាចនឹងបន្តកើនឡើងនៅពេលដែលម្ចាស់ជំនួយកាត់បន្ថយជំនួយ ហើយវានឹងធ្វើប្រទេសកម្ពុជារងគ្រោះដូចប្រទេសក្រិចដែរ។

## កសិករនៅស្រុកសំពៅលូនប្រឈមនឹងបញ្ហាដោយសារគ្រោះរាំងស្ងួត

*(វិទ្យុអាស៊ីសេរី ១៦ ឧសភា ២០១០)*

ឆ្នាំនេះគ្រោះរាំងស្ងួតបានបំផ្លាញផលដំណាំរបស់កសិករជាច្រើនគ្រួសារនៅស្រុកសំពៅលូន ខេត្តបាត់ដំបង។ អាជ្ញាធរស្រុកសំពៅលូនបានឱ្យដឹងថា ប្រជាពលរដ្ឋនៅក្នុងស្រុកនេះមានចំនួនជាង ៦ពាន់គ្រួសារក្នុងនោះមានជាង ៩៥%ជាកសិករដែលនិយមធ្វើកសិកម្មដាំពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង និងដាំល្ង លើផ្ទៃដីកសិកម្មសរុបទំហំ ២ម៉ឺន១ពាន់ហិកតានៅក្នុងស្រុក។ អាជ្ញាធរបន្តថា កសិករប្រមាណ ៥០%នៅពេលរដូវដាំដុះពួកគេបាននាំគ្នាទៅខ្ចីលុយពីធនាគារ ឬអង្គការផ្សេងៗយកទៅធ្វើដើមទុន ដើម្បីទិញគ្រាប់ពូជ ភ្ជួររាស់ និងជួលកម្លាំងពលកម្មដាំដុះ។

## ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័យកើនឡើង

*(ភ្នំពេញប៉ុស្តិ៍ ១៣ ឧសភា ២០១០)*

អគ្គនាយកនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានប្រសាសន៍ឱ្យដឹងថា ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅប្រទេសកម្ពុជាមានការកើនឡើងលើពីឆ្នាំទៅ។ ទិន្នន័យបង្ហាញថា មានអ្នកប្រើប្រាស់សរុបចំនួន ៦.៣លាននាក់នៅត្រឹមចុងឆ្នាំ ២០០៩ ដែលនៅឆ្នាំ ២០០៨ មានត្រឹម ៣.៨ លាននាក់។

## សាច់ប្រាក់សុទ្ធជាង៣៦លានដុល្លារត្រូវបានពលករកម្ពុជាផ្ញើមកក្រុមគ្រួសាររយៈពេលមួយឆ្នាំ

*( រស្មីកម្ពុជា ១១ ឧសភា ២០១០)*

មន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទានិយាយឱ្យដឹងថាក្នុងឆ្នាំ២០០៩កន្លងមកពលករ ពលការិនីកម្ពុជាដែលចេញទៅធ្វើការងារនៅប្រទេសចំនួនបីរួមមានម៉ាឡេស៊ី កូរ៉េ និងថៃ យ៉ាងតិចក៏បានផ្ញើសាច់ប្រាក់សុទ្ធប្រមាណជាង ៣៦ លានដុល្លារអាមេរិកមកឱ្យក្រុមគ្រួសារនៅក្នុងប្រទេសដែរ ។

បើតាមមន្ត្រីអគ្គនាយកដ្ឋានការងារនៃក្រសួងការងារបញ្ជាក់ឱ្យដឹងបន្ថែមទៀតថាតាមតួលេខជាផ្លូវការនៅឆ្នាំ២០០៩គឺមានពលករ ពលការិនីចេញទៅធ្វើការនៅប្រទេសទាំងបីខាងលើចំនួន១៤.៥០៤នាក់ ក្នុងនោះនាឆ្នាំ២០០៩គឺមានពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ីចំនួន៩៦៨២នាក់ ។ ពួកគេទៅធ្វើការងារជាកិច្ចការផ្ទះនិងការងារតាមរោងចក្រសហគ្រាស ។ ទីផ្សារពលកម្មកម្ពុជានៅម៉ាឡេស៊ីពីដំបូងបញ្ជូនទៅធ្វើការតែកិច្ចការផ្ទះប៉ុន្តែជាងមួយឆ្នាំកន្លងមកក៏បានបញ្ជូនទៅធ្វើការងាររោង

ចក្រអេឡិចត្រូនិច រោងចក្រ សហគ្រាស និងសិប្បកម្មផងដែរ ។ ដោយឡែកទីផ្សារនៅប្រទេសកូរ៉េ ពលករ ពលការិនីកម្ពុជាបានចូលធ្វើការខាងវិស័យឧស្សាហកម្ម សិប្បកម្មមធ្យម និងសិប្បកម្មខ្នាតតូចជាដើម ។

## ដើមឆ្នាំ២០១០ពលករកម្ពុជាចេញទៅធ្វើការនៅក្រៅប្រទេសកើនឡើង

*( រស្មីកម្ពុជា ១០ ឧសភា ២០១០)*

តាមតួលេខជាផ្លូវការបញ្ជាក់ឱ្យដឹងថាគិតចាប់ពីខែមករាដល់ខែមេសាឆ្នាំ២០១០ ពលករ-ពលការិនីបញ្ជូនចេញទៅធ្វើការស្របច្បាប់នៅប្រទេសម៉ាឡេស៊ីមានចំនួន២៦០៧នាក់បើគិតក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០០៩ មានចំនួនត្រឹម២១២០នាក់តែប៉ុណ្ណោះ ។ប្រទេសកូរ៉េបានធ្លាក់កិច្ចសន្យាមកជាបន្តបន្ទាប់មានចំនួនជាង៥០០នាក់ បើធៀបនឹងដើមឆ្នាំកន្លងមកពុំមានម្នាក់ទេ ។ នេះអាចចាត់ទុកថាជាការល្អប្រសើរជាងឆ្នាំមុនថ្វីត្បិតប្រទេសកូរ៉េទើបតែធ្លាក់កិច្ចសន្យាពុំទាន់បានបញ្ជូនពលករទៅធ្វើការនៅទីនោះ ក៏ដោយ ។នេះបើតាមការឱ្យដឹងពីមន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាកាលពីរសៀលថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ។

## ក្រុមហ៊ុនចំនួន៧បានទទួលដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាល

*( រស្មីកម្ពុជា ១០ ឧសភា ២០១០)*

ក្រុមហ៊ុនទាំង៧ដែលទទួលបាននូវដីសម្បទានសេដ្ឋកិច្ចនេះមានទី១-ក្រុមហ៊ុនភីអិលធីខូអិលធីឌី ទទួលផ្ទៃដីចំនួន៧៩០០ហិកតានៅស្រុករវៀង ខេត្តព្រះវិហារសម្រាប់ការដាំដុះកៅស៊ូ ទី២-ក្រុមហ៊ុនស៊ី អ ស៊ី ខេ អភិវឌ្ឍន៍កៅស៊ូទទួលផ្ទៃដីចំនួន៦០៤៤ហិកតានៅស្រុកសណ្តាន់ខេត្តកំពង់ធំសម្រាប់ដំណាំកៅស៊ូ ទី៣-ក្រុមហ៊ុនហួរលីងទទួលផ្ទៃដីចំនួន៧៧៧៣ហិកតានៅស្រុកអូររាំងឪ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី សម្រាប់ដាំដើមស្រល់ ទី៤-ក្រុមហ៊ុនស៊ីស៊ីវី ទទួលដីចំនួន៩៧៣០ហិកតានៅស្រុកសន្ទុក ខេត្តកំពង់ធំ សម្រាប់ដំណាំអាកាស្យា ទី៥-ក្រុមហ៊ុនអាយ ភី ឌី អ៊ិនស្ទេន ប្រូត្រេឌីងទទួលដីចំនួន៩៨៧ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះសម្រាប់ការដាំកៅស៊ូ ទី៦-ក្រុមហ៊ុនខេមទ្រី ឧបភើរសេនិទទួលដីចំនួន២៨០៩ហិកតានៅស្រុកឈូក ខេត្តកំពតសម្រាប់ដាំដើមប្រេងខ្យល់ និងទី៧-ក្រុមហ៊ុនក្រុងប៊ុក រតនគិរីអភិវឌ្ឍន៍កៅស៊ូទទួលដីចំនួន៦៦៩៥ហិកតានៅស្រុកអណ្តូងមាស ខេត្ត រតនគិរី សម្រាប់ដាំកៅស៊ូ ។

## កម្ពុជានាំចូលប្រេងឥន្ធនៈមានតម្លៃរហូតដល់៤៥០លានដុល្លារក្នុង១ឆ្នាំ

*( រស្មីកម្ពុជា ០៦ ឧសភា ២០១០)*

ក្នុងមួយឆ្នាំប្រទេសកម្ពុជាបានចំណាយលើការនាំចូលប្រេងឥន្ធនៈ មានតម្លៃរហូតដល់ប្រមាណជាជិត៤៥០លានដុល្លារ ។ របាយការណ៍មួយរបស់ក្រសួងពាណិជ្ជកម្មដែលរស្មីកម្ពុជាទើបតែទទួលបានកាលពីពេលថ្មីៗកន្លងទៅនេះបានឱ្យដឹងថានៅក្នុងមួយឆ្នាំការនាំចូលប្រេងឥន្ធនៈមានតម្លៃប្រមាណជា ៤៤៩.១៥៤.៧៦៥ដុល្លារនៅក្នុងបរិមាណប្រមាណជា ៨៨២.៧២៤តោន។ របាយការណ៍នោះបានបញ្ជាក់ថាការចំណាយលើប្រេងឥន្ធនៈរបស់កម្ពុជាគឺជាការចំណាយលើការនាំចូលធំទីពីររបស់កម្ពុជាខណៈដែលការនាំចូលធំបំផុតគឺជាវត្ថុធាតុដើមសម្រាប់បម្រើវិស័យឧស្សាហកម្មកាត់ដេរ ។ ប្រភពដដែលនោះបានឱ្យដឹងថាការ

ចំណាយលើប្រេងឥន្ធនៈគឺមានតម្លៃលើសពីតម្លៃនៃការនាំចូលឱសថ និងបរិក្ខារពេទ្យព្រមទាំងម្ហូបអាហារផងដែរ ។ ការនាំចូលបរិក្ខារពេទ្យនិងឱសថគឺមានចំនួនត្រឹមតែប្រមាណជាជិត១០៧លានដុល្លារហើយការនាំចូលម្ហូបអាហារវិញគឺមានតម្លៃប្រមាណជា១០៦.៦លានដុល្លារ។ ចំណែកឯការនាំចូលវត្ថុធាតុដើមលើវិស័យឧស្សាហកម្មកាត់ដេរគឺមានតម្លៃប្រមាណជា ១.៥០៧ លានដុល្លារ ។

## តម្លៃស្រូវដាំក្បាលចុះ,វៀតណាមផ្អាកការទិញពីកម្ពុជា

*(រស្មីកម្ពុជា ០៦ ឧសភា ២០១០)*

ភ្នាក់ងារសហគ្រាសរបស់អង្គការសេដាកលោកនង សំអាត បាននិយាយនៅថ្ងៃនេះថាតម្លៃស្រូវក្នុងស្រុកកំពុងធ្លាក់ចុះតាំងពីខែមីនាមកម្ល៉េះ ។ ឥឡូវនេះតម្លៃស្រូវធម្មតាបានមកនៅត្រឹម៨៥០រៀលទៅ៩០០រៀលក្នុងមួយគីឡូក្រាម ។ កាលពីដើមឆ្នាំឬពេលរដូវប្រមូលផលស្រូវវស្សាថ្លៃ១០៥០ទៅ១១០០រៀលក្នុងមួយគីឡូក្រាម ។ ឈ្មួញកណ្តាលក្នុងស្រុកដែលទិញស្រូវស្តុកទុកកំពុងភ័យពីការខាតបង់ ។ សូម្បីតែស្រូវរបស់សមាជិកសហគមន៍របស់អង្គការសេដាកដែលប្រមូលទិញស្រូវផលិតតាមគោលការណ៍ធម្មជាតិស្តុកទុកសម្រាប់បម្រើឱ្យទីផ្សារក្នុងស្រុកក៏ព្រួយពីការខាតបង់របស់ខ្លួនដែរ ។

កម្ពុជាឆ្នាំនេះមានស្រូវសល់ប្រមាណជាង៣លានតោនក្រៅពីការហូបចុកក្នុងប្រទេសដែលអាចធ្វើការនាំចេញឬផលិតជាអង្ករនាំចេញបាន ។

## ក្រុមហ៊ុនផលិតជីរបស់វៀតណាម សម្លឹងមើលឳកាសជំនួញនៅកម្ពុជា

*(វិទ្យុបារាំង ០៥ ឧសភា ២០១០)*

ក្រុមហ៊ុនសាជីវកម្មផលិតជី អ៊ុយរ៉េ របស់ប្រទេសវៀតណាមដែលមានតម្លៃវិនិយោគ ៣៧០លានដុល្លារគម្រោងនឹងបើកសម្ពោធធ្វើការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្មជីកសិកម្ម។ តំណាងក្រុមហ៊ុនបានប្រកាសថា ការប្រើប្រាស់ជី អ៊ុយរ៉េ បានបង្កើនទិន្នផលស្រូវរបស់កសិករកម្ពុជាពី ២.៥តោនក្នុងមួយហិកតា ទៅដល់ ៨.៦ តោនក្នុងមួយហិកតា ហើយមិនប៉ះពាល់ដល់បរិស្ថានទេ។ ប៉ុន្តែតំណាក្រុមហ៊ុនបន្តថា បើសិនជាប្រើជីកសិកម្មនេះច្រើនលើសកម្រិត វាក៏អាចធ្វើឱ្យដីកសិកម្មរឹងខូចគុណភាពដែរ។

## ថៃនាំផ្លែឈើចូលកម្ពុជាក្នុងមួយឆ្នាំ ១០០លានបាត

*(កោះសន្តិភាព ០៤ ឧសភា ២០១០)*

ថៃបាននាំចូលផ្លែឈើមកកាន់ទីផ្សារកម្ពុជាក្នុងមួយឆ្នាំៗគិតជាទឹកប្រាក់ប្រហែល ១០០លានបាត ដែលការនាំចូលនេះមានការកើនឡើង ២៥%ជារៀងរាល់ឆ្នាំ។

## ផលិតផលពីបក្សីខូចគុណភាពនៅតែបន្តលួចនាំចូលខុសច្បាប់

*(រស្មីកម្ពុជា ០៤ ឧសភា ២០១០)*

ផលិតផលបក្សី ដែលកម្ពុជាហាមនាំចូល ឬចរាចរណ៍លក់ដូរក្នុងស្រុកនោះ នៅតែបន្តមានលួចនាំចូលនៅតាមច្រកប៉ោយប៉ែត។ ជាក់ស្តែងកាលពីថ្ងៃទី ៣០ មេសាកន្លងទៅ សមត្ថកិច្ចបានបង្ក្រាបចាប់បានសាច់មាន់ទម្ងន់ ២៥០ គីឡូក្រាម ប្រហិតសាច់ត្រីខូចគុណភាព ៥០ គីឡូក្រាម និងពងទាចំនួន ១០០គ្រាប់ ដែលលួចនាំចូល។

## សត្វគ្រួច និងត្រីប្រាខូចគុណភាពជាង ៥តោនត្រូវប៉ូលិសបង្ក្រាប

*(រស្មីកម្ពុជា ០២ ឧសភា ២០១០)*

សត្វគ្រួចបោចរោម និងត្រីប្រាជាង ៥តោនខូចគុណភាពដែលឈ្មួញលួចនាំចូលខុសច្បាប់ពីប្រទេសវៀតណាម តាមច្រកបាវិត ខេត្តស្វាយរៀង យកមកចែកចាយនៅរាជធានីភ្នំពេញ ត្រូវបានប៉ូលិសស្ទាក់ចាប់បាននៅចំណុចកំពង់ចំលងអ្នកលឿង។

## នៅកម្ពុជាមានមនុស្សប្រមាណ ១៥០០ នាក់ស្លាប់រៀងរាល់ឆ្នាំពាក់ព័ន្ធនឹងការបំពេញការងារ

*(រស្មីកម្ពុជា ០២ ឧសភា ២០១០)*

នៅប្រទេសកម្ពុជាមនុស្សប្រមាណ ១៥០០នាក់ ត្រូវបានគេប៉ាន់ប្រមាណថា បានស្លាប់ជារៀងរាល់ឆ្នាំដោយសារគ្រោះថ្នាក់ពាក់ព័ន្ធនឹងការងារ មានន័យថា មានមនុស្សស្លាប់ ៤នាក់ក្នុងមួយថ្ងៃ។